**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខៈ ០៧៧/១៦ គណជ

# កំណត់ហេតុស្តីពី
# លទ្ធផលកិច្ចប្រជុំត្រីមាសទី១ ឆ្នាំ២០១៦
# របស់
# គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)
# ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៦
# សាលប្រជុំ អគារ A ក្រសួងមហាផ្ទៃ

ឆ្នាំពីរពាន់ដប់ប្រាំមួយ ខែឧសភា ថ្ងៃទីដប់ វេលាម៉ោង ប្រាំបី និងសាមសិប នាទីព្រឹក មានបើកកិច្ចប្រជុំត្រីមាសទី១ ឆ្នាំ២០១៦ របស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)។

## ប្រសាសន៍សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)

- ខ្ញុំសូមជម្រាបជូនព័ត៌មានបន្ទាន់មួយដែលពាក់ព័ន្ធ នឹងការដឹកនាំកម្លាំងធ្វើបាតុកម្ម ពីបណ្តាអង្គការមួយចំនួន ឲ្យមានការស្លៀកពាក់ពណ៌ខ្មៅ ដែលចោទថារដ្ឋាភិបាលបានបំបិទសិទ្ធិសេរីភាព និងរំលោភសិទ្ធិមនុស្ស។ ដោយមានការណែនាំផ្ទាល់ពី **សម្តេចតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងសុំជាអនុសាសន៍ដើម្បីធ្វើការដោះស្រាយការងារនេះឲ្យបានល្អ ដើម្បីកុំឲ្យបញ្ហានេះបន្តរីករាលដាលទៅមុខទៀត ក៏បានធ្វើការបញ្ចុះបញ្ចូលពួកគាត់ឲ្យត្រឡប់ទៅផ្ទះវិញ ហើយបញ្ជូនលិខិតដែលពួកគាត់ទាមទារនោះទៅស្ថាប័នពាក់ព័ន្ធ។ យើងបានបន្តការងារ និងខិតខំពិនិត្យមើលសភាពការណ៍នេះយ៉ាងម៉ត់ចត់ តាមគ្រប់មធ្យោបាយដូចជាៈ ដោះស្រាយតាមផ្លូវច្បាប់ តែបើយើងបណ្តែតបណ្តោយតទៅទៀតនោះ វានឹងធ្វើឲ្យសភាពការណ៍ឡើងកម្តៅនៅលើឆាកអន្តរជាតិ។ យើងបានប្រកាសព័ត៌មាននេះនៅចំថ្ងៃទិវាកាកបាទក្រហម ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៦ ហើយយើងបានរៀបចំការងារនេះជាកញ្ចប់មានមធ្យោបាយសរុប កម្លាំងសរុប បូករួមទាំងថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តទៅតាមតួនាទីរៀងៗខ្លួន និងមានការគ្រប់គ្រងមន្ត្រីរាជការរបស់យើងដោយបានប្រគល់ ការងារនេះទៅឲ្យ **ឯកឧត្តម សុខ អាន** ជាអ្នករៀបចំយន្តការនេះ ដើម្បីធ្វើការតាមដានបន្តទៅទៀត ហើយម្សិលមិញនេះយើងបានដោះស្រាយការងារនេះបានល្អ។
- **របៀបវារៈ** នៃកិច្ចប្រជុំមាន៖ យើងបន្តកិច្ចប្រជុំត្រីមាសទី១ ឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) វាមានការយឺតយ៉ាវបន្តិចបន្តួច ដោយសារក្រសួង ស្ថាប័ន

ពាក់ព័ន្ធមួយចំនួន នៅពេលអនុវត្តជួបនូវការលំបាកលើរបាយការណ៍ពាក់ព័ន្ធ និងលើទិន្នន័យសរុប។ យើងជួបបញ្ហាលំហូរទេសន្តរប្រវេសន៍ ជាពិសេសបណ្តាប្រទេសនៅអឺរ៉ុប ហើយចំពោះការស្វែងរកដៃគូដើម្បីរៀបការជាមួយជនបរទេស គឺមិនមានឯកសារច្បាស់លាស់ ដែលក្លាយជាបន្ទុករបស់រដ្ឋាភិបាលប្រទេសជាសាមី។ ទាក់ទងនឹងប្រទេសកម្ពុជា មានពលករទៅធ្វើការនៅប្រទេសថៃ ទាំងស្របច្បាប់ និងមិនស្របច្បាប់ ហើយបានទាក់ទងទៅនឹងរដ្ឋាភិបាលប្រទេសថៃ ឲ្យជួយរៀបចំតាមច្បាប់ត្រឹមត្រូវមានជាងកន្លះលាន នាក់។

- យើងបានរៀបចំធ្វើលិខិតឆ្លងដែន សម្រាប់ពលកររបស់យើងដែលទៅធ្វើការនៅបរទេស ជាពិសេសប្រទេសថៃ វាមានបញ្ហាខ្លះៗ រឿងបុគ្គលនៅក្នុងជួររដ្ឋាភិបាលថៃ ពាក់ព័ន្ធលើការជួញដូរមនុស្ស ហើយនៅប្រទេសកូរ៉េ មានការងាយស្រួលក្នុងរឿងឯកសារ បទដ្ឋានគតិយុត្តិ សម្រាប់ពលករកម្ពុជា។ រដ្ឋាភិបាលកម្ពុជា បានព្រមព្រៀងជាមួយរដ្ឋាភិបាលប្រទេសអូស្រ្តាលី ក្នុងការទទួលយកជនភៀសខ្លួន ហើយមានអង្គការមួយចំនួនបានចោទប្រកាន់រដ្ឋាភិបាលយើង។ ការទទួលយកជនភៀសខ្លួនមួយនាក់ ឬពីរនាក់បានសម្រេចមកកម្ពុជា និងមួយចំនួនទៀតមិនចង់មកប្រទេសកម្ពុជាទេ ដែលយើងបានធ្វើកិច្ចសម្ភាសន៍ជាមួយគាត់ និងធ្វើការជាមួយ UNHCR ធ្វើសម្ភាសន៍ជាមួយ ឲ្យគេទទួលយកទៅប្រទេសគេវិញ។
- យើងបានដាក់ចេញនូវគោលការណ៍ណែនាំ ០៦ ចំណុច សម្រាប់អនុវត្តន៍ការងារ ជាពិសេសរឿងទេសន្តរប្រវេសន៍ ដើម្បីទប់លំហូរពលករទៅធ្វើការនៅក្រៅប្រទេស ដោយបានរៀបចំច្រកមួយចំនួនដែលមានព្រំប្រទល់ជាប់ប្រទេស ថៃ វៀតណាម ឡាវ ខ្ញុំបានដាក់បញ្ជាឲ្យបិទច្រកទាំងអស់នោះ ដោយសារមានពលករចេញតាមច្រកទ្វារមានជាង មួយលាន នាក់ ទៅក្រៅប្រទេសដែលជាបញ្ហាធ្លាក់ទៅលើក្រសួងសង្គមកិច្ច និង រដ្ឋាភិបាលយើងផងដែរ។
- សូមដាក់ជូនក្រុមការងារទាំង ០៦ ដោយលើកយោបល់ឆ្លុះបញ្ចាំងអំពីការងារដែលជួបការលំបាក ការងាយស្រួល ហើយយន្តការនេះនៅរាយប៉ាយនៅឡើយ ដោយមិនទាន់បានប្រមូលផ្តុំពីក្រសួង ស្ថាប័នទាំងអស់ធ្វើការសហការគ្នាលើរបាយការណ៍រួមមួយ យើងមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រុមការងារទាំង០៦ នៅថ្នាក់ក្រោមជាតិ យើងមានលេខាធិការដ្ឋាន រាជធានី/ខេត្ត ក្រុង/ស្រុក ឃុំ/សង្កាត់ និងមានមន្ត្រីមួយចំនួនបានបម្រើការងារនៅទីនោះដែរ។ រដ្ឋាភិបាលបានផ្តល់ជាមធ្យោបាយរួចរាល់ហើយ តែនៅកន្លែងខ្លះការអនុវត្តការងារមិនបានល្អនៅឡើយ និងមិនទាន់ទទួលបានលទ្ធផល និងមានប្រសិទ្ធភាពខ្ពស់នៅឡើយ។
- ប្រទេសកម្ពុជា ធ្លាប់មានស្លាកស្នាមជាមួយប្រទេសម៉ាឡេស៊ី រឿងពលករទៅបម្រើការងារនៅទីនោះ។ ពាក់ព័ន្ធនឹងការធ្វើរបាយការណ៍ នៅតាមក្រុមនីមួយៗរបស់ស្ថាប័ន-ក្រសួង មានភារកិច្ចទទួលខុសត្រូវរៀងៗខ្លួន ទោះបីក្រសួង-ស្ថាប័នមានការប្រជុំមមាញឹក ច្រើនកន្លែងជាន់គ្នាយ៉ាងណាក៏ដោយ ប្រធានក្រុមការងារត្រូវដឹកនាំក្រសួងជាសមាជិករៀបចំធ្វើរបាយការណ៍ ដោយមានការប្រជុំពិភាក្សាគ្នា ដើម្បីធ្វើការសម្របសម្រួលលើការងារនេះ។ បើមានការទាក់ទងចុះ MOU ជាមួយបណ្តាប្រទេសផ្សេងៗ ថាតើក្រសួងណាជាប្រធាន ហើយធ្វើការប្រជុំព្រាងអនុស្សរណៈជាមួយក្រសួងជាសមាជិក វាមិនខុសទេផ្លូវច្បាប់។ ក្រសួងនីមួយៗជាអ្នកទទួលខុសត្រូវចំពោះរដ្ឋាភិបាល និងធ្វើការឆ្លើយបំភ្លឺទៅរដ្ឋសភាជាតិ រឿងជួញដូរមនុស្ស និងការពាក់ព័ន្ធទៅនឹងរបាយការណ៍នោះ សូមឲ្យអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានដឹងដើម្បីបន្តធ្វើសេចក្តីព្រាងរបាយការណ៍ និងធ្វើការសម្របសម្រួល។

**លោកជំទាវ ជូ ប៊ុនអេង**

**រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

- លោកជំទាវ បានឡើងអានរបាយការណ៍ត្រីមាសទី១ ឆ្នាំ២០១៦ តាមរយៈការបញ្ចាំងជា Slide ដែលមានចំនួន ១៣ទំព័រ ស្តីពី សកម្មភាពការងាររបស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ដោយបានទទួលចំណារពីសម្តេចផ្ទាល់ រឿងពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងជាមួយប្រទេសឥណ្ឌា បានធ្វើការសម្របសម្រួលជាមួយបណ្តាអន្តរក្រសួង-ស្ថាប័នពាក់ព័ន្ធ អំពីការងារអន្តោប្រវេសន៍ ការជួញដូរមនុស្ស ដែលមាននណាខ្លះដឹកនាំប្រជុំការងារនេះ? គឺមានការពាក់ព័ន្ធជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវជាង ហើយមុននឹងមានការចុះហត្ថលេខា គួរមានការស្រុះស្រួលគ្នាជាមុន ប៉ុន្តែរាល់កិច្ចការទាំងអស់នេះត្រូវបានធ្វើការសម្របសម្រួលជាមួយអគ្គលេខាធិការដ្ឋាន។
- បញ្ហាពាក់ព័ន្ធការចុះ MOU ជាមួយរដ្ឋាភិបាលចិន យើងបានពិភាក្សាការងារជាមួយស្ថាប័នមួយចំនួន ស្តីពីការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋកម្ពុជា ជាមួយពលរដ្ឋចិន (និយាយរួមគឺ បញ្ហាជួយជនរងគ្រោះដោយអំពើជួញដូរ) ដោយបញ្ជាក់លើលិខិតស្នាម ភូមិ/ឃុំ ថានៅលីវ ហើយអាចចុះបញ្ជីអាពាហ៍ពិពាហ៍បាន ហើយនរណាជាអ្នកទទួលខុសត្រូវលើរឿងនេះពិតប្រាកដ? យើងកំពុងតែមានការព្រួយបារម្ភមួយ នៅពេលមានការពិភាក្សាជាមួយគ្នា ចំពោះច្បាប់ប្រទេសចិន គឺគេឲ្យខាងស្រីទៅរស់នៅខាងប្រុស តាមប្រពៃណីទំនៀមទម្លាប់គ្រួសារត្រូវតែអនុវត្ត។ តើយើងត្រូវជួយជនរងគ្រោះជាអ្នកណាខ្លះ? ហើយភាគីទាំងពីរត្រូវមានគោលជំហររួមគ្នាតែមួយ ដោយធ្វើកិច្ចសហប្រតិបត្តិការរួមគ្នាចំពោះពលករ។

**លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួង កិច្ចការនារី**

- លោកជំទាវ បានមានប្រសាសន៍សង្កត់ធ្ងន់ទៅលើបញ្ហាធ្វើរបាយការណ៍ៈ ការបង្កើនសមត្ថភាពពេលធ្វើរបាយការណ៍ពុំទទួលបានរបាយការណ៍គ្រប់គ្រាន់ពីសមាជិក នៃក្រសួង-ស្ថាប័នពាក់ព័ន្ធនៅឡើយ គឺទទួលបានតែ០៤ ក្រសួង-ស្ថាប័នតែប៉ុណ្ណោះ។
- បញ្ហាសមាជិកមួយរូបអាចមានក្រុមការងារច្រើនស្ថាប័ន ច្រើនកន្លែង ដែលមិនមានពេលគ្រប់គ្រាន់ក្នុងការមកជួបជុំពិភាក្សាអំពីបញ្ហាជួញដូរមនុស្ស និងផ្តល់របាយការណ៍តាមការកំណត់របស់ក្រុមការងារបាន។
- បញ្ហាពាក់ព័ន្ធ កិច្ចសហប្រតិបត្តិការអន្តរជាតិ កម្ពុជា-ចិន សុំឲ្យមានការសហការជាមួយគ្នា និងត្រូវផ្តល់ព័ត៌មានដែលពាក់ព័ន្ធឲ្យគ្នាទៅវិញទៅមក។
- លោកជំទាវ មានប្រសាសន៍បន្ថែមថាៈ ក្រសួងកិច្ចការនារី នឹងរៀបចំធ្វើសេចក្តីព្រាងដើម្បីចុះ MOU ជាមួយប្រទេសម៉ាឡេស៊ី នាពេលខាងមុខ។

**ឯកឧត្តម ឡុង វិសាលោ**

**រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

- ខ្ញុំមានការឯកភាពតាមប្រសាសន៍ របស់លោកជំទាវរដ្ឋមន្ត្រី ក្រសួងកិច្ចការនារី។
- អំពីបញ្ហាតួលេខខុសគ្នារវាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ ព្រោះក្រសួងការបរទេស តែងតែយកព័ត៌មានតាមរយៈស្ថានទូត ហើយធ្វើរបាយការណ៍លម្អិតជូនក្រសួងមហាផ្ទៃ ឲ្យជ្រាបដើម្បីរៀបចំទទួល ធ្វើសមាហរណកម្មត្រឡប់មកវិញដែរ ដូច្នេះហើយទើបមានតួលេខខុសគ្នា រីឯក្រសួងមហាផ្ទៃទទួលតួលេខតាមការជាក់ស្តែង (ឧ).ពេលពលករវិលមកតាមរយៈច្រកទ្វារអន្តរជាតិ តាមយន្តហោះ ក្រសួងការបរទេសដឹង តែបើពលករវិលមកតាមច្រកព្រំដែនតូចៗនានា នគរបាលអន្តោប្រវេសន៍គាត់ដឹង ហើយបញ្ជូនតួលេខមកក្រសួងមហាផ្ទៃ តែក្រសួងការបរទេស

មិនបានដឹង ដូច្នេះធ្វើឲ្យតួលេខមានការខុសគ្នាឆ្ងាយ។ ខ្ញុំសូមឲ្យមានកិច្ចសហប្រតិបត្តិការគ្នាល្អ ផ្តល់ព័ត៌មានឲ្យគ្នាទៅវិញទៅមក ដើម្បីឲ្យព័ត៌មានទាំងសងខាងត្រូវគ្នា។

- បញ្ហាថៃ ថាបានចេញសេចក្តីប្រកាសបន្តប័ណ្ណពណ៌ស៊ីជម្ពូ ឲ្យពលករដែលអាចឲ្យអ្នកនៅក្នុងបន្ទុកមានសិទ្ធិទៅរស់នៅជាមួយពលករបានដូចជា ប្រពន្ធ កូន ចៅ...។ល។ ចាប់ពីឆ្នាំ២០១៧ ដើម្បីអូសទាញពលករកម្ពុជាឲ្យទៅបម្រើការងារនៅទីនោះ។
- បញ្ហាម៉ាឡេស៊ី កំពុងធ្វើការរៀបចំពលករដែលទៅធ្វើការខុសច្បាប់ ឲ្យក្លាយជាពលករស្របច្បាប់ ដែលជាបញ្ហាមួយត្រូវប្រុងប្រយ័ត្នបារម្ភ ព្រោះថាអាចមានពលករខ្លះ គាត់បានឆ្លងដែនតាមប្រទេសថៃ ទៅម៉ាឡេស៊ីតែម្តង រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ គេនឹងរឹតបន្តឹងហើយធ្វើការចាប់បញ្ជូនត្រឡប់មកវិញដូចលើកមុនទៀត នេះជាបញ្ហាដែលយើងត្រូវគិតគូរ។
- បញ្ហាចិន កន្លងមកមានស្ត្រីខ្មែរជាច្រើនត្រូវបានជួញដូរដោយមេខ្យល់ទៅប្រទេសចិន តាមរយៈការរៀបការ ហើយក្រសួងមហាផ្ទៃ ក៏មានការចាប់ខ្លួនមេខ្យល់បានមួយចំនួនផងដែរ ដែលមេខ្យល់បានទិញ ក្នុងនោះក៏មានការស្ម័គ្រចិត្តផងដែរ ព្រោះសង្ឃឹមថាអាចរកលុយបាន និងមានលទ្ធភាពជួយដល់គ្រួសារនៅស្រុកខ្មែរ តែមិនដូចចិត្តក៏ទៅប្តឹងស្ថានទូតថាខ្លួនត្រូវចាញ់បោកគេតាមរយៈការជួញដូរ។
- ប៉ុន្តែអ្វីដែលគួរឲ្យកោតសរសើរខ្លាំងបំផុត ហើយជាចំណុចវិជ្ជមានផងដែរ ដែលបានបង្កើតច្បាប់រៀបការនេះឡើងរវាងជនបរទេស និងពលរដ្ឋខ្មែរ ក្នុងការទប់ស្កាត់អំពើជួញដូរមនុស្សពីប្រទេសកម្ពុជា។

**លោកជំទាវ ឧត្តមសេនីយ៍ឯក យក់ សុខា អគ្គស្នងការរងនគរបាលជាតិ**

- អំពីសកម្មភាពរបស់ក្រុមការងារអនុវត្តច្បាប់ ដែលដឹកនាំដោយ **ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន** ជាប្រធាន មានសមាសភាពចំនួន ១៧រូប មកពីអន្តរក្រសួង អ្វីដែលនាងខ្ញុំចង់ជម្រាបជូននៅពេលនេះគឺ នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៥ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ បានរៀបចំប្រជុំក្រុមការងារលើកទី១ ក្រោមអធិបតីភាព **ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន** អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ដើម្បីបង្ហាញអំពីតួនាទីភារកិច្ចរបស់ខ្លួន និងឲ្យមានការសហការគ្នាក្នុងការអនុវត្តការងារក្នុងក្រុម។ លើកទី២ នៃកិច្ចប្រជុំគឺ ធ្វើនៅ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៥ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលបានពិនិត្យឆ្លងនូវសេចក្តីព្រាង នៃផែនការសកម្មភាពរបស់ក្រុមអនុវត្តច្បាប់ ហើយបានដាក់ឆ្លង និងចុះហត្ថលេខាដោយ ឯកឧត្តមប្រធាន និងបានបញ្ជូនមក គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ រួចរាល់។ លើកទី៣ កិច្ចប្រជុំបានធ្វើឡើងនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦។
- លោកជំទាវមានប្រសាសន៍ឯកភាព ចំពោះប្រសាសន៍របស់លោកជំទាវរដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងឯកឧត្តមរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្តីពីបញ្ហាប្រឈមមួយចំនួនដូចគ្នាដែលក្រុមការងារអនុវត្តន៍ច្បាប់ បានជួបផងដែរ ជាពិសេសការធ្វើរបាយការណ៍ និងការចូលរួមប្រជុំក្នុងក្រុមការងារ។
- មួយទៀតដែរចំពោះប្រសាសន៍ ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងការបរទេស ដែលលោកលើកពីបញ្ហា **ឯកឧត្តម រដ្ឋមន្ត្រីក្រសួងការបរទេស** បានជួបជាមួយនារីរងគ្រោះនៅប្រទេសចិន ហើយបានបញ្ជូនមកវិញ យើងបានចាត់កម្លាំងនៅក្នុងនាយកដ្ឋានដើម្បីស៊ើបអង្កេត ករណីនេះបានចុះទៅស្រាវជ្រាវដល់មូលដ្ឋានរបស់ជនរងគ្រោះ ក្រោយមកយើងបានចាប់ខ្លួនជនសង្ស័យចំនួនពីររូប ដែលជាប្តីប្រពន្ធនឹងគ្នា ហើយបានបញ្ជូនពួកគេទៅតុលាការនៅ ខែកុម្ភៈ ឆ្នាំ២០១៦។

- បញ្ហាមួយទៀតគឺ ភាពខុសគ្នានូវតួលេខ រវាងអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងការបរទេស ដូចប្រសាសន៍របស់ ឯកឧត្តម រដ្ឋលេខាធិការក្រសួងការបរទេស គឺអគ្គស្នការដ្ឋាននគរបាលជាតិ បានទទួលរបាយការណ៍ពីស្ថានទូត ក៏ដូចជាក្រសួងការបរទេសផងដែរ មួយផ្នែកទៀតគឺទទួលបានពីស្នងការដ្ឋាននគរបាលខេត្តជាប់ព្រំដែន ជាពិសេសខេត្តបន្ទាយមានជ័យ និងខេត្តស្វាយរៀង ទើបមានការខុសតួលេខគ្នាយ៉ាងនេះ។

**ឯកឧត្តម អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

- ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានមានប្រសាសន៍លើកឡើងអំពីការងារពាក់ព័ន្ធសម្រាប់ក្រុមការងារបាននឹងកំពុងរៀបចំធ្វើសេចក្តីព្រាងច្បាប់ ចំណុចខ្វះខាតនៃច្បាប់បង្ក្រាបអំពើជួញដូរមនុស្ស ដោយធ្វើការពិភាក្សាជាមួយស្ថាប័ន ក្រសួងមួយចំនួន ហើយមានច្បាប់ពីរទៀតគឺៈ ច្បាប់ នីតិវិធីការពារសាក្សីដោយសុំជំនួយពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ច្បាប់មួយទៀតនិយាយពីការស៊ើបអង្កេតសម្ងាត់សម្រាប់ស្រាវជ្រាវ ការលាងលុយកខ្វក់។ ក្រសួងយុត្តិធម៌ នឹងមានបើកវគ្គបណ្តុះបណ្តាលដល់ផ្នែកនៃស្ថាប័នមួយចំនួនទាក់ទងនឹងអំពើជួញដូរមនុស្ស។
- ចំពោះបញ្ហាទាក់ទងការយឺតយ៉ាវក្នុងការជំនុំជម្រះ កំពុងពិនិត្យមើលរចនាសម្ព័ន្ធការងារ។

**ឯកឧត្តម ឡុង វិសាលោ**
**រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

- ខ្ញុំបាទសូមគាំទ្រទាំងស្រុងចំពោះ មណ្ឌលសំចត ប៉ោយប៉ែតគួរតែមាន មិនបាច់ពឹងពាក់លើភាគីថៃទេ ព្រោះថៃវាមានគំនិតខូច បញ្ហាមណ្ឌលសំចតនេះខ្ញុំក៏ចង់ឲ្យមានឆាប់ៗនេះដែរ យើងគួរទទួលធ្វើខ្លួនយើងតែម្តងទៅ តែខ្ញុំគាំទ្រណាស់ដើម្បីទទួលយកពួកគេមកវិញ និងបន្តវិជ្ជាជីវៈសម្រាប់រស់នៅលើទឹកដីខ្មែរ។

**ឯកឧត្តម ជូ វិជិត្ត រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- មានការឯកភាព និងគាំទ្រចំពោះការសាងសង់មណ្ឌលសំចត ដោយមិនចាំបាច់ពឹងពាក់ការសន្យារបស់ភាគីថៃទេ បើយើងពិនិត្យមើលប៉ុន្មានឆ្នាំហើយ ដែលយើងតស៊ូជាមួយថៃ តែមិនមានលទ្ធផលអ្វីសោះ។
- ឯកឧត្តមមានប្រសាសន៍បន្ថែមទៀតថា ការស្នើសុំសាងសង់មណ្ឌលសំចតនៅប៉ោយប៉ែតនេះ ក្រសួងសង្គមកិច្ច បានស្នើសុំឲ្យរដ្ឋាភិបាលថៃជួយលើរឿងនេះជាការសាងសង់អគារ។ ប៉ុន្តែអ្នកម៉ៅការសាងសង់របស់ថៃ គេបានស្នើសុំនាំគ្រឿងសម្ភារៈសំណង់ចូលដោយមិនបាច់បង់ពន្ធជូនរដ្ឋទេ។ ហេតុដូច្នេះក្រសួងហិរញ្ញវត្ថុមិនអាចអនុញ្ញាតឲ្យបានទេ។ ពាក់ព័ន្ធនឹងគម្រោងនេះ សូមឲ្យក្រសួងសង្គមកិច្ច លើកជាគម្រោងថវិកាសម្រាប់សាងសង់អគារមណ្ឌលសំចត សម្រាប់ទទួលពលករតាមច្រកស្នាក់នៅជាបណ្តោះអាសន្ន មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីទម្លាក់កញ្ចប់ថវិកាដេញថ្លៃសាងសង់។

**លោកជំទាវ ខៀវ បូរី រដ្ឋលេខាធិការក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន**

លោកជំទាវ រដ្ឋលេខាធិការ បានមានប្រសាសន៍ឆ្លើយតបទាក់ទងទៅនឹងសំណួររបស់ **សម្តេចក្រឡាហោម** ពាក់ព័ន្ធបញ្ហាមណ្ឌលសំចតព្រៃស្គី ថាៈ មានការប្រមូលតាមតំបន់ភ្នំពេញទៅដាក់នៅកន្លែងនោះហើយមានការបណ្តុះបណ្តាល អប់រំ និងបានរៀបចំសារឡើងវិញ ដោយសារខ្វះខាតថវិកាប្រើប្រាស់។ ដោយមានការចេញ-ចូល នៃចំនួនអ្នកទាំងនោះ ធ្វើឲ្យការទទួលតួលេខមិនបានច្បាស់លាស់។ លោកជំទាវមានប្រសាសន៍បន្តទៀតថា ក្រសួងសង្គមកិច្ច មានកន្លែង(ដី) សម្រាប់សាងសង់អគារមណ្ឌលសំចតប៉ោយប៉ែតហើយ ប៉ុន្តែមិនទាន់មានថវិកាសម្រាប់សាងសង់អគារ។

**សម្តេចក្រឡាហោម ស ខេង**

ខ្ញុំឯកភាពអំពីការលើកឡើងរបស់ លោកជំទាវ រដ្ឋមន្ត្រីក្រសួងកិច្ចការនារី លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ (គ.ជ.ប.ជ) ឯកឧត្តម រដ្ឋលេខាធិការក្រសួងការបរទេស ឯកឧត្តម រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមការងារទាំង០៦ អំពីបញ្ហាសាងសង់មណ្ឌលសំចតនៅ ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ នឹងត្រូវប្រគល់ការកិច្ចនេះជូនក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន ជាអ្នកទទួលខុសត្រូវ (បោះមេ) ដោយមានការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

**ចុងក្រោយ:** ខ្ញុំសូមសរសើរដល់ក្រុមការងារមួយចំនួន ដែលខិតខំធ្វើការងារយ៉ាងសកម្ម លើការងាររបាយការណ៍ ហើយក្រុមការងារមួយចំនួនអត់មានសកម្មភាពនេះ គួរតែមានការជំរុញការងារនេះបន្ថែមទៀត ដោយធ្វើការសហការគ្នាជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ។ ការពាក់ព័ន្ធលើរបាយការណ៍ ប្រចាំខែ ត្រីមាស ឆមាស អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាអ្នកប្រមូលរបាយការណ៍បូកសរុប ឲ្យចេញជាលទ្ធផល។ ចំពោះការងារចុះ **MOU** ជាមួយបណ្តាប្រទេសមួយចំនួន គួរតែឲ្យក្រសួងណាមួយជាអ្នកទទួលបន្ទុករៀបចំការងារនេះ ត្រូវមានការឯកភាពគ្នាជាមួយស្ថាប័នដទៃទៀត និងជាមួយអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដើម្បីទទួលសិទ្ធិពីរដ្ឋាភិបាល។

យើងគួររៀបចំបណ្តុះបណ្តាលថ្នាក់រដ្ឋមន្ត្រីសម្រាប់ក្រុមការងារនៅតាម ស្ថាប័ន-ក្រសួង ហើយនឹងមានការវាយតម្លៃនៅពាក់កណ្តាលអាណត្តិ ឆ្នាំ២០១៦នេះ ដោយអគ្គលេខាធិការដ្ឋានជាអ្នកប្រមូលរាល់ឯកសារទាំងអស់មកធ្វើការបូកសរុបឲ្យបានល្អ។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង ដប់មួយ និងដប់ប្រាំនាទី ថ្ងៃ ខែ ឆ្នាំដដែល។

រាជធានីភ្នំពេញ ថ្ងៃទី..១៧.. ខែ..ធ្នូ.. ឆ្នាំ២០១៦

**អ្នកកត់ត្រា**

ឧត្តមសេនីយ៍ត្រី គង់ ពុទ្ធី

បានឃើញ និងឯកភាព

ថ្ងៃទី..២១.. ខែ..ធ្នូ.. ឆ្នាំ២០១៦

**អនុប្រធានអចិន្ត្រៃយ៍**

ជូ ប៊ុនអេង